# ធម្មនុញ្ញ និងលក្ខន្តិកៈរបស់កតិកាសញ្ញាជនជាតិដើមភាគតិចអាស៊ី

អនុម័តដោយសេចក្តីសំរេចរបស់អង្គមហាសន្និបាតលើកទី៦ របស់អេអាយភីភី
នៅថ្ងៃទី ៨ ខែកញ្ញា ឆ្នាំ២០១២

## លំនាំដើម

យើងទាំងអស់គ្នាជាស្ថាប័ននិងចលនារបស់ជាតិដើមភាគតិចនៅក្នុងតំបន់អាស៊ីបានរួមគ្នាជាផ្លូងមួយដោយការគោរពនិងជឿទុកចិត្តគ្នាទៅវិញទៅមកដោយចែករំលែក ពិភាក្សា និងឆ្លុះបញ្ចាំងយ៉ាងស៊ីជំរៅទៅលើអតីតកាល ស្ថានភាពបច្ចុប្បន្ន ការព្រួយបារម្ភ និងសេចក្តីប្រាថ្នា របស់សហគមន៍ជនជាតិដើមភាគតិច តាមរយៈការប្តេជ្ញាចិត្ត ក្នុងការទាមទារសិទ្ធដីធ្លី ដីកេរ្តិ៍ដូនតា និងសិទ្ធស្វ័យសំរេចដើម្បីការពារ ប្រើប្រាស់និង អភិវឌ្ឍន៍នូវធនធាននិងទឹកដីរបស់យើង ដោយសមស្របទៅតាមប្រពៃណី វប្បធម៌របស់យើង សូមអនុម័តនិងប្រកាសអោយប្រើនូវ ធម្មនុញ្ញ និងលក្ខន្តិកៈនេះចាប់ពីពេលនេះតទៅ។

## មាត្រា ១ ឈ្មោះស្ថាប័ន

**ផ្នែកទី១** ស្ថាប័ននេះមានឈ្មោះថា កតិកាសញ្ញាជនជាតិដើមភាគតិចអាស៊ី ដែលហៅកាត់ថា អេអាយភីភី (AIPP)។

## មាត្រា ២ ការិយាល័យ

**ផ្នែកទី១** ការកំណត់ទីតាំងស្នាក់ការលេខាធិការដ្ឋានរបស់ អេអាយភីភី គឺអាស្រ័យទៅលើការសំរេចរបស់មហាសន្និបាត។

## មាត្រា៣ ផ្លាកសញ្ញាសំគាល់ និងត្រា

**ផ្នែកទី១** និមិត្តសញ្ញារបស់ស្ថាប័ន

រូបក្រណាត់ត្បាញនៅក្នុងនិមិត្តសញ្ញាតំណាងអោយភាពជាបងប្អូនរបស់ជនជាតិ ដើមភាគតិច ទាំងប្រុសទាំងស្រីនៅក្នុងតំបន់អាស៊ី ដែលជាការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក ដោយភាពសុខដុមរម្យនា។ រូបនេះក៏តំណាងអោយភាពសម្បូរបែបនៃវប្បធម៌របស់ជនជាតិដើម ភាគតិចផងដែរ។ នៅក្នុងរូបនោះផងដែរពាក្យកាត់AIPP ត្របាញ់ចូលគ្នាដែលបង្ហាញអំពីតួនាទីនិងអត្ថន័យនៃភាពថិតថេររបស់កតិកាសញ្ញានេះ។ ចំពោះពិណក្រហមវិញគឺជាពិណមួយដែលនិយមចូលចិត្តពីសំណាក់ជនជាតិដើមភាគតិចនៅតំបន់អាស៊ីដែលជានិមិត្តសញ្ញានៃកំលាំងរួមគ្នា និងសាមគ្គីភាពក្នុងតស៊ូរើបំរ៉ះរបស់ជនជាតិដើមភាគតិច។ ចំពោះរូបភាពផ្កាយពិណសនៅខាងឆ្វេងនិងខាងស្តាំនៃនិមិត្តសញ្ញានេះតំណាងអោយសមាសភាពអនុតំបន់របស់កតិកាសញ្ញា អេអាយភីភី។ អក្សរ AIPP ដែលមានពិណបៃតង តំណាងអោយប្រព័ន្ធបរិស្ថានរបស់ជនជាតិដើមភាគតិច។

## មាត្រា៤ ការចុះឈ្មោះ និងការទទួលស្គាល់

**ផ្នែកទី១** ស្ថាប័ននេះបានចុះឈ្មោះស្របច្បាប់ជាមូលនិធិ (មូលនិធិកតិកាសញ្ញាជនជាតិដើមភាគតិចអាស៊ី) នៅក្រុងឈៀងម៉ៃ ប្រទេសថៃក្នុងនាមជា ស្ថាប័នក្រៅរដ្ឋាភិបាល មិនរកប្រាក់ចំនេញពីក្រសួងវប្បធម៌របស់ប្រទេសថៃចាប់តាំងពីឆ្នាំ២០០៥មកម្លេះ។

**ផ្នែកទី២** អេអាយភីភី ត្រូវបានទទួលស្គាល់ជា អង្គការក្រៅរដ្ឋាភិបាលនៅក្នុង ការពិគ្រោះយោបល់ពិសេសជាមួយក្រុមប្រឹក្សាសង្គមនិងសេដ្ឋកិច្ចរបស់អង្គការសហប្រជាជាតិ តាំងពី ខែមិថុនា ឆ្នាំ ២០១២។

**ផ្នែកទី៣** អេអាយភីភី ក៏ត្រូវបានទទួលស្គាល់ជាផ្លូវការផងដែរដោយអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការបំរែបំរួលអាកាសធាតុ (UNFCCC) ក្នុងឆ្នាំ២០១១ និងដោយអង្គការសហប្រជាជាតិស្តីពីកម្មសិទ្ធបញ្ញា(WIPO) ក្នុងខែកក្កដា ឆ្នាំ២០១២។

## មាត្រា៥ ចរិកលក្ខណៈរបស់ស្ថាប័ន

**ផ្នែកទី១** ចរិកលក្ខណៈរបស់ អេអាយភីភី គឺជាសហព័ន្ធថ្នាក់តំបន់នៃស្ថាប័នជនជាតិដើមភាគតិច ដែលតំណាងអោយចលនាជនជាតិដើមភាគតិច នៅក្នុង តំបន់អាស៊ីដែលបង្កើតឡើងដើម្បីសម្រប សម្រួល គាំទ្រ និងពង្រឹងនូវសាមគ្គីភាព និងមិត្តភាពក្នុងចំណោមអង្គការជា សមាជិក និងចលនាផ្សេងៗរបស់ជនជាតិដើមភាគតិច។

## មាត្រាទី៦. គោលបំណង

**ផ្នែកទី១** ជាស្ថាប័នមួយបង្កើតឡើងដើម្បីចែករំលែក សេចក្តីប្រាថ្នា គំនិត និងបទពិសោធន៍គ្នាទៅវិញទៅមក ព្រមទាំងសម្របសម្រួលអោយមានសហប្រតិបត្តិការ សាមគ្គីភាព និងធានាអោយមានរបៀបវារៈ សកម្មភាព និងកម្មវិធីដូចគ្នា ដោះស្រាយបញ្ហាដែលប៉ះពាល់ដល់ជនជាតិដើមភាគតិចនៅក្នុងតំបន់អាស៊ី។

**ផ្នែកទី២** បង្កើនសមត្ថភាពសហគមន៍ ស្ថាប័ន អង្គការ រួមទាំងស្ត្រីនិងយុវជន ជនជាតិដើមភាគតិចដើម្បីឆ្លើយតបទៅនិងបញ្ហា និងការព្រួយបារម្ភរបស់ពួកគេនៅគ្រប់កំរិតផ្សេងៗគ្នា។

**ផ្នែកទី៣** បង្កើតនូវកម្មវិធីដោយផ្អែកទៅលើបញ្ហាយុទ្ធសាស្រ្តជាចំបង និងតំរូវការរបស់អង្គការសមាជិក។

**ផ្នែកទី៤** តស៊ូមតិទៅលើបញ្ហារបស់ជនជាតិដើមភាគតិចនៅគ្រប់កំរិតព្រមទាំងចូលរួមពាក់ព័ន្ធជាមួយគ្រប់ដំណើរការថ្នាក់ជាតិ តំបន់ និងអន្តរជាតិ ក៏ដូចជាមួយស្ថាប័ននិងភ្នាក់ងារនានា។

**ផ្នែកទី៥** ពង្រឹងទំនាក់ទំនង កសាងបណ្តាញ សហការជាមួយអង្គការដែលធ្វើការងារតស៊ូមតិ និងគាំទ្រស្ថាប័ន និងចលនាដទៃទៀត ដើម្បីទាមទារអោយមានការទទួលស្គាល់នូវបំណងប្រាថ្នា (ការចង់បាន) របស់ជនជាតិដើមភាគតិចនៅក្នុងតំបន់អាស៊ី ក៏ដូចជាចូលរួមចំណែកធ្វើអោយសំរេចបាននូវភាពស្មើគ្នា សន្តិភាព លទ្ធិប្រជាធិប្បតេយ្យ និង យុត្តិធម៌សង្គម។

## មាត្រាទី៧. ទស្សនៈវិស័យ បេសកកម្ម និងគោលដៅរបស់ អេអាយភីភី

**ផ្នែកទី១ ទស្សនៈវិស័យៈ** ជនជាតិដើមភាគតិចនៅអាស៊ីអនុវត្តសិទ្ធិដោយពេញលេញ អនុវត្តអត្តសញ្ញាណនិងវប្បធម៌ដែលប្លែកពិសេស និងរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ ព្រមទាំងធ្វើអោយប្រសើរឡើងនូវ ប្រព័ន្ធគ្រប់គ្រងទឹកដីនិងធនធានប្រកបដោយនិរន្តភាពសំរាប់ អនាគត និងការអភិវឌ្ឍន៍ដែលមានសន្តិភាព យុត្តិធម៌ និងសមធម៌ របស់ពួកគេផ្ទាល់។

**ផ្នែកទី២ បេសកកម្មៈ** ពង្រឹងនូវសាមគ្គីភាព សហប្រតិបត្តិការនិងសមត្ថភាពជនជាតិដើមភាគតិច នៅតំបន់អាស៊ី ដើម្បីលើកកំពស់និងការពារ សិទ្ធិ អត្តសញ្ញាណនិងវប្បធម៌ ប្រព័ន្ធគ្រប់គ្រងធនធានដោយនិរន្តរភាពរបស់ពួកគេសំរាប់ការអភិវឌ្ឍន៍ និងសិទ្ធិស្វ័យសំរេច(សំរេចចិត្តដោយខ្លួនឯង)។

**ផ្នែកទី៣** គោលដៅៈ

៣.១ ផ្តល់អំណាចដល់ជនជាតិដើមភាគតិចនៅ តំបន់អាស៊ីដើម្បីលើកពួកគេលើកតំកើង និងការពារ សិទ្ធិមនុស្ស សេរីភាពជាមូលដ្ឋាននានា និងអាចទាមទារការទទួលស្គាល់ដោយស្របច្បាប់ចំពោះ អត្តសញ្ញាណ សិទ្ធិសមូហភាពរបស់ពួកគេដែល មានចែង នៅក្នុងសេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច និងលិខិតុបករណ៍ សិទ្ធិមនុស្សអន្តរជាតិផ្សេងៗទៀត។

៣.២ កសាងនូវសាមគ្គីភាព និងកិច្ចសហប្រតិបត្តិការដ៏ទូលំទូលាយក្នុងចំណោម ជនជាតិដើមភាគតិចនៅតំបន់អាស៊ីដើម្បីពង្រឹងនូវចលនាជនជាតិដើមភាគតិច។

៣.៣ លើកកំពស់ និងការពារសេចក្តីថ្លៃថ្នូរនិងតំលៃរបស់ធម្មជាតិ និងបរិស្ថានដោយធ្វើអោយប្រសើឡើងនូវប្រព័ន្ធគ្រប់គ្រងធនធានប្រកបដោយនិរន្តរភាពរបស់ជនជាតិដើមភាគតិចរួមទាំងចំណេះដឹងជាលក្ខណៈប្រពៃណី សុវត្ថិភាពស្បៀង ជីវៈចំរុះតាមរយៈការទទួលបាននូវសិទ្ធិពេញលេញក្នុងការគ្រប់គ្រង ដីធ្លី ដែនដី និងធនធានធម្មជាតិរបស់ពួកគេ។

៣.៤ជនជាតិ ដើមភាគតិច ជាពិសេសស្ត្រីនិងយុវជនបាន ចូលរួមពេញលេញ និងដោយមានប្រសិទ្ធភាពនៅគ្រប់កំរិតនៃការសំរេចចិត្ត។

៣.៥ ពង្រឹងសាមគ្គីភាពនិងកិច្ចសហប្រតិបត្តិការជាមួយចលនាសង្គមដទៃទៀតឆ្ពោះទៅរកការសំរេចបាននូវ សមភាព សន្តិភាព លទ្ធិប្រជាធិប្បតេយ្យ និងយុត្តិធម៌សង្គម។

## មាត្រា ៨ សមាជិកភាព

**ផ្នែកទី១** សមាជិកភាពរបស់ អេអាយភីភី គឺបើកទូលាយសំរាប់គ្រប់ប្រភេទនៃអង្គការនិងចលនាជនជាតិដើមតិច រួមទាំងអង្គការស្ត្រីនិងយុវជនជនជាតិដើមភាគតិចដែលមានទីតាំងនៅក្នុងតំបន់អាស៊ី និងដែលយល់ស្របទៅនិងគោលបំណងនិងគោលដៅរបស់ អេអាយភីភី។

**ផ្នែកទី២** គ្រប់អង្គការនិងចលនាសង្គមនានារបស់ជនជាតិដើមភាគតិចដែលមានបំណងចូលជាសមាជិករបស់ អេអាយភីភី តំរូវអោយបំពេញនូវពាក្យស្នើសុំ និងផ្តល់នូវព៌តមានអំពីអង្គការរបស់ខ្លួនទៅក្រុមប្រឹក្សាប្រតិបត្តិដែលជាអ្នកសំរេចចិត្តចំពោះសមាជិកភាព។ ការសំរេចចិត្តចុងក្រោយចំពោះសមាជិកភាពនឹងត្រូវធ្វើឡើងនៅក្នុងពេលមហាសន្និបាត។

**ផ្នែកទី៣** សមាជិកភាពត្រូវបានគេបែងចែកជាបីប្រភេទអាស្រ័យតាមកំរិតនៃអង្គការ ឬចលនាសង្គម:

- ប្រភេទមូលដ្ឋាន(អង្គការមូលដ្ឋាន ឬអង្គការសហគមន៍ ឬចលនាសង្គមនានា)
- ប្រភេទក្រោមជាតិ (អង្គការ ឬចលនាសង្គមដែលធ្វើការនៅកំរិតខេត្ត)
- ប្រភេទថ្នាក់ជាតិ (អង្គការឬចលនាសង្គមដែលធ្វើការនៅកំរិតថ្នាក់ជាតិ)

**ផ្នែកទី៤** ល័ក្ខខ័ណ្ឌសមាជិកភាពត្រូវពិចារណាទៅតាមតម្រូវការ និងភាពដែលអាចគ្រប់គ្រងបានគិតទៅតាម ស្ថាប័ន លក្ខណៈភូមិសាស្ត្រ និងធានាអោយមានការចូលរួមពីអង្គការស្ត្រី និងយុវជន។

## មាត្រា ៩ បណ្តាញរបស់ អេអាយភីភី

**ផ្នែកទី១** អេអាយភីភី ត្រូវដើរតួនាទី ជាបណ្តាញ និងត្រូវបង្កលក្ខណៈងាយស្រួយក្នុងការទំនាក់ទំនងជាមួយអង្គការជនជាតិដើមភាគតិចដទៃៗទៀត ដែលចង់ចងបណ្តាញជាមួយ អេអាយភីភី ដោយ មិនចង់ចូលជាសមាជិក។ អេអាយភីភី អាចអញ្ជើញសមាជិកបណ្តាញប្រភេទនេះ អោយចូលរួមក្នុងកម្មវិធី និងសកម្មភាពនានាដោយចាត់ទុកដូចជា ដៃគូរគម្រោងរបស់ អេអាយភីភី និងអាចទទួលបាននូវព៌តមានទាន់ហេតុការណ៍ និងរបាយការណ៍នានាដោយទៀងទាត់។

**ផ្នែកទី២** អេអាយភីភី ត្រូវកោះប្រជុំជាមួយនិងសមាជិក ដៃគូរគម្រោង និងសមាជិកបណ្តាញតាមអនុតំបន់នីមួយៗនៅក្នុងចន្លោះពេលមានមហាសន្និបាតដើម្បីពិគ្រោះយោបល់ទៅលើបច្ចុប្បន្នភាព

នៃការអភិវឌ្ឍន៍ បញ្ហានិងការព្រួយបារម្ភដែលជាអាទិភាព តាមអនុតំបន់នីមួយៗ និងដើម្បីពិនិត្យឡើងវិញនូវ កម្មវិធីនិងផែនការ យន្តការសម្របសម្រួល និងបញ្ហាដទៃៗទៀតដែលសមស្របជាមួយនឹង គោលបំណងរបស់ អេអាយភីភី។

## មាត្រា ១០ មហាសន្និបាត

**ផ្នែកទី១** អង្គការសមាជិកទាំងអស់របស់ អេអាយភីភី ត្រូវចូលរួមក្នុងមហាសន្និបាតតាមរយៈការចាត់តំណាងពីស្ថាប័នរបស់ខ្លួន។

**ផ្នែកទី២** មហាសន្និបាតគឺជាឱកាសខ្ពស់បំផុតសំរាប់ការសំរេចចិត្តរបស់ស្ថាប័ន។

**ផ្នែកទី៣** រាល់ការសំរេចចិត្តក្នុងពេលមហាសន្និបាតត្រូវធ្វើឡើងដោយការឯកភាពក្នុងចំណោមអ្នកតំណាងពីអង្គការជាសមាជិក។

**ផ្នែកទី៤** មហាសន្និបាតនឹងត្រូវគេធ្វើរៀងរាល់៥ឆ្នាំម្តងដែលដឹកនាំដោយក្រុមប្រឹក្សាប្រតិបត្តិ។

**ផ្នែកទី៥** មហាសន្និបាតនឹងជ្រើសរើសក្រុមប្រឹក្សាប្រតិបត្តិ។

## មាត្រា ១១ ក្រុមប្រឹក្សាភិបាលរបស់មូលនិធិ អេអាយភីភី

**ផ្នែកទី១** សមាសភាពសមាជិកក្រុមប្រឹក្សាភិបាលរបស់ មូលនិធិ អេអាយភីភី នឹងត្រូវជ្រើសចេញពីប្រជាជននៃប្រទេសដែលលេខាធិការដ្ឋានបោះទីតាំងយោងទៅតាមច្បាប់ និងដោយយោងទៅតាមឆន្ទះរបស់បុគ្គលនោះក្នុងការគាំទ្រជនជាតិដើមភាគតិច ដើម្បីសំរេចគោលដៅ និងគោលបំណងរបស់ អេអាយភីភី។ សមាសភាពសមាជិកក្រុមប្រឹក្សាភិបាលក៏អាចជ្រើសរើសចេញពីអតីតប្រធាននិងអគ្គលេខាធិការរបស់ អេអាយភីភី។

**ផ្នែកទី២** សមាសភាពរបស់ក្រុមប្រឹក្សាភិបាលរួមមានៈ ប្រធាន អនុប្រធាន លេខា និងហេរញ្ញិកដែលជាប្រជាជនរបស់ប្រទេសដែលលេខាធិការដ្ឋានតាំងនៅ និង សមាជិកក្រុមប្រឹក្សាភិបាលដទៃទៀត។

## មាត្រា ១២ ក្រុមប្រឹក្សាប្រតិបត្តិ

**ផ្នែកទី១** ក្រុមប្រឹក្សាប្រតិបត្តិជាអ្នកសំរេចចិត្តសំរាប់ស្ថាប័នក្នុងចន្លោះមហាសន្និបាត។

**ផ្នែកទី២** សមាសភាពក្រុមប្រឹក្សាប្រតិបត្តិរួមមាន:

- អ្នកដឹកនាំដែលបានជ្រើសតាំងដោយត្រឹមត្រូវ មកពីអនុតំបន់នីមួយៗដែល អេអាយភីភីបានកំណត់។ សមាជិកនៅតាមអនុតំបន់នីមួយៗជាអ្នកធ្វើការជ្រើសរើសអ្នកដឹកនាំរៀងៗខ្លួន។
- សមាជិកត្រូវជ្រើសរើសប្រធាន និងអគ្គលេខាធិការដោយផ្ទាល់ពីអង្គមហាសន្និបាត។
- យុវជន និងស្ត្រីត្រូវចាត់តាំងអ្នកតំណាងរបស់ខ្លួន២នាក់ដើម្បីសុំអនុម័តពីមហាសន្និបាត។
- អង្គមហាសន្និបាតត្រូវយកចិត្តទុកដាក់អំពីសមតុល្យយ៉ែនឌ័រនៅក្នុងសមាសភាពក្រុមប្រឹក្សាប្រតិបត្តិ។

**ផ្នែកទី៣** ក្រុមប្រឹក្សាប្រតិបត្តិមានអាណត្តិបួន(៤)ឆ្នាំ ដោយស្របជាមួយនឹងពេលវេលាចន្លោះមហាសន្និបាត។ ក្រុមប្រឹក្សាប្រតិបត្តិអាចធ្វើយ៉ាងយូត្រឹម២អាណត្តិជាប់គ្នា។

## មាត្រា ១៣ លេខាធិការដ្ឋាន

**ផ្នែកទី១** លេខាធិការដ្ឋានស្ថិតនៅក្រោមការគ្រប់គ្រងរបស់ អគ្គលេខាធិការដែលត្រូវទទួលខុសត្រូវក្នុងការអនុវត្តន៍កម្មវិធី និងសកម្មភាពរបស់ អេអាយភីភី ដោយ សហការជិតស្និទ្ធជាមួយក្រុមប្រឹក្សាប្រតិបត្តិ សមាជិក ដៃគូរគម្រោង និងបណ្តាញផ្សេងៗរបស់ អេអាយភីភី។

**ផ្នែកទី២** សមាសភាពសមាជិក លេខាធិការដ្ឋានត្រូវតែជ្រើសរើសចេញពីជនជាតិដើមភាគតិចនៅក្នុងតំបន់អាស៊ី ដែលមានគុណសម្បត្តិនិងលក្ខណៈសម្បត្តិគ្រប់គ្រាន់សំរាប់អនុវត្តការងារ។

**ផ្នែកទី៣** អគ្គលេខាធិការរងត្រូវជ្រើសតាំងដោយអគ្គលេខាធិការ ដោយពិភាក្សាជាមួយក្រុមប្រឹក្សាប្រតិបត្តិ ដើម្បីជួយគ្រប់គ្រង និងចាត់ចែងការងាររបស់លេខាធិការដ្ឋាននិងការអនុវត្តន៍នូវសកម្មភាពនិងគោលដៅជាក់លាក់។

**ផ្នែកទី៤** សមាជិកលេខាធិការដ្ឋានត្រូវទទួលខុសត្រូវដោយផ្ទាល់ទៅអគ្គលេខាធិការ និងក្រុមប្រឹក្សាប្រតិបត្តិ។

## មាត្រា ១៤ វិសោធនកម្ម (ការកែប្រែ)

**ផ្នែកទី១** ធម្មនុញ្ញ និងលក្ខន្តិកៈរបស់ អេអាយភីភី អាចនឹងត្រូវគេធ្វើវិសោធនកម្ម លុបចោល ឬបំផ្លែងទាំងស្រុង ឬដោយ ផ្នែកណាមួយ លុះណាមានសំលេងគាំទ្រពីរភាគបី (២/៣) នៃសមាជិកដែលមានវត្តមាននៅក្នុងពេលមហាសន្និបាត។

# លក្ខន្តិកៈរបស់កតិកាសញ្ញាជនជាតិដើមភាគតិចអាស៊ី

## មាត្រា ១  ផលប្រយោជន៍ សិទ្ធិ និងបុព្វសិទ្ធិ របស់សមាជិក

**ផ្នែកទី១** គ្រប់អង្គការ និងចលនាសង្គមនានារបស់ជនជាតិដើមភាគតិចដែលចង់ចូលជា សមាជិករបស់ អេអាយភីភី តំរូវអោយបំពេញនូវពាក្យស្នើសុំ និងផ្តល់នូវពិតមានអំពីស្ថាប័ន របស់ខ្លួនទៅក្រុមប្រឹក្សាប្រតិបត្តិ ដែលជាអ្នកពិនិត្យចំពោះសមាជិកភាព។ ការសំរេចចិត្តចុងក្រោយចំពោះសមាជិកភាពនឹងត្រូវធ្វើឡើងពេលអង្គមហាសន្និបាត។

**ផ្នែកទី២** ការបង់ថវិកាប្រចាំឆ្នាំរបស់សមាជិកគឺអាស្រ័យទៅតាមប្រភេទនៃសមាជិកភាព:

- $ 20: ប្រភេទមូលដ្ឋាន(អង្គការមូលដ្ឋាន ឬអង្គការសហគមន៍ ឬចលនាសង្គមនានា)
- $ 35: ប្រភេទក្រោមជាតិ (អង្គការ ឬចលនាសង្គមដែលធ្វើការនៅកំរិតខេត្ត)
- $ 50: ប្រភេទថ្នាក់ជាតិ (អង្គការឬចលនាសង្គមដែលធ្វើការនៅកំរិតថ្នាក់ជាតិ)

**ផ្នែកទី៣** សមាជិកល្អមានសិទ្ធិ និងបុព្វសិទ្ធិដូចតទៅ:

ក. សមាជិកភាពនឹងត្រូវគេព្យួរប្រសិនបើសមាជិកណាមួយធ្វើសកម្មភាពផ្ទុយពីធម្មនុញ្ញលក្ខន្តិកៈ សេចក្តីណែនាំ និងគោលនយោបាយរបស់ អេអាយភីភី។ ក្រុមប្រឹក្សាប្រតិបត្តិនឹងព្យួរសមាជិកភាពជាបណ្តោះអាសន្នដោយធ្វើការពិភាក្សាជាមួយសមាជិកដទៃទៀតដែលនៅក្នុងអនុតំបន់ដូចគ្នា។ មហាសន្និបាតជាអ្នកសំរេចចុងក្រោយក្នុងការដកសមាជិកភាព។

ក្រុមប្រឹក្សាប្រតិបត្តិនឹងចាត់ទុកសមាជិកណាមួយថាអសកម្មនៅពេលដែលសមាជិកនោះមិនមានទំនាក់ទំនងជាមួយលេខាធិការដ្ឋានតំបន់ និងមិនបានចូលរួមសកម្មភាពជាមួយ អេអាយភីភីចាប់ពីពីរឆ្នាំឡើងទៅ។ លេខាធិការដ្ឋាននឹងជូនដំណឹងដល់សមាជិកនោះតាមរយះសំបុត្រ។ មហាសន្និបាតនឹងពិនិត្យឡើងវិញនូវសមាជិកណាដែលអសកម្ម និងសំរេចចុងក្រោយថាត្រូវដក ឬព្យួរសមាជិកភាពរបស់សមាជិកណាមួយ។ សមាជិកដែលត្រូវគេព្យួរ ឬដកសមាជិកភាពអាចស្នើសុំចូលជាសមាជិកឡើងវិញតាមរយះក្រុមប្រឹក្សាប្រតិបត្តិ។

ខ. សមាជិកមានសិទ្ធិក្នុងការបញ្ចេញទស្សនៈយល់ឃើញ អំពីប្រតិបត្តិការអេអាយភីភីដោយអាចរាយការណ៍ទៅក្រុមប្រឹក្សាប្រតិបត្តិ និងមហាសន្និបាត អំពីភាពមិនប្រក្រតី បញ្ហា និងការប្រឹងប្រែងតស៊ូនានារបស់ជនជាតិដើមភាគតិច។

គ. សមាជិកមានសិទ្ធិចូលរួមជាមួយ គណកម្មាធិការកម្មវិធី និង យន្តការផ្សេងៗដែលបង្កើតឡើងដោយ អេអាយភីភី ក្នុងការផ្តល់យោបល់ និងពិនិត្យអំពីសកម្មភាព និងកម្មវិធីអេអាយភីភី ដូចជាការធ្វើផែនការ ការអនុវត្តន៍ និងការវាយតំលៃ។

ឃ. សមាជិកត្រូវទទួលបាននូវអាទិភាពក្នុងការចូលរួមរាល់សកម្មភាព និងកម្មវិធីរបស់អេអាយភីភី នៅថ្នាក់ជាតិ តំបន់ និងថ្នាក់អន្តរជាតិ អាស្រ័យទៅតាមស្ថានភាពជាក់ស្តែង និងមានថវិកា។

ង. សមាជិកត្រូវទទួលបាននូវអាទិភាពធ្វើជាដៃគូរការងារផ្ទាល់ ដោយមានការគាំទ្រថវិការដើម្បីអនុវត្តកម្មវិធី និងគំរោងនានាដែលសមស្រប។

ច. សមាជិកមានសិទ្ធិក្នុងការទទួលបាននូវការគាំទ្រដោយផ្ទាល់ និងប្រយោល ដូចជាការគាំទ្រផ្នែកបច្ចេកទេស សម្ភារៈ និងថវិកាជាដើមសំរាប់ឆ្លើយតបនឹងបញ្ហាជាអាទិភាពរបស់អង្គការសមាជិក អាស្រ័យទៅតាមសមត្ថភាពរបស់ក្រុមប្រឹក្សាប្រតិបត្តិ លេខាធិការដ្ឋាន និង មានធនធាន និងថវិកា។

ឆ. សមាជិកមានសិទ្ធិក្នុងការចូលរួមប្រជុំតាមអនុតំបន់របស់ អេអាយភីភី ដើម្បីចែករំលែកបទពិសោធន៍ កំណត់បញ្ហារបស់ជនជាតិដើមភាគតិច ផ្តល់មតិកែលំអរលើសកម្មភាពរបស់អេអាយភីភីដែលបានធ្វើដោយបុគ្គលិកលេខាធិការដ្ឋាន និងផ្តល់មតិសំរាប់កម្មវិធីរបស់អេអាយភីភី កំណត់សកម្មភាពនានាសំរាប់ពង្រឹងស្ថាប័ន ឧទាហរណ៍ យន្តការសំរាប់សម្របសម្រួល និងទំនាក់ទំនងជាដើម។ល។

ជ. សមាជិកមានសិទ្ធិទទួលបាននូវរាល់ឯកសារបោះពុម្ភ និងសម្ភារៈនានាដែលផលិតដោយ អេអាយភីភី។

ឈ. សមាជិកមានសិទ្ធិទទួលកំណត់ហេតុនៃកិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិ និងឯកសារផ្សេងៗដែលទាក់ទងនិង អេអាយភីភីតាមការស្នើសុំ។ ឯកសារទាំងនោះរួមមាន របាយការណ៍ទូទៅ របាយការណ៍ហិរញ្ញវត្ថុ សំណើសុំថវិកា។ល។

**ផ្នែកទី៤** សមាជិកត្រូវមានតួនាទី និងការទទួលខុសត្រូវដូចខាងក្រោមៈ

ក. សមាជិកត្រូវរក្សាទំនាក់ទំនងជាមួយលេខាធិការដ្ឋាន និងក្រុមប្រឹក្សាប្រតិបត្តិ ព្រមទាំងរាយការណ៍ជូនអំពីបច្ចុប្បន្នភាព នៃការអភិវឌ្ឍន៍ស្ថាប័ន ពិតមាន និងសកម្មភាពនានាដោយធ្វើអោយប្រសើរឡើងនូវយន្តការនៃការចែកចាយចំណេះដឹងនិងពិតមាន។

ខ. សមាជិកត្រូវលើកកំពស់គោលដៅ និងគោលបំណងរបស់ អេអាយភីភី តាមរយៈការចូលរួមដោយ ពេញលេញជាមួយនិងសកម្មភាព និងកម្មវិធីរបស់ អេអាយភីភី ដោយត្រូវបង់ថវិកាសំរាប់សមាជិកភាពរបស់ខ្លួន។

គ. សមាជិកដែលជាដៃគូអនុវត្តន៍កម្មវិធី ឬគំរោង របស់ អេអាយភីភីត្រូវអនុវត្តអោយបានត្រឹមត្រូវស្របតាមកិច្ចសន្យាដែលបានចុះហត្ថលេខារវាង អេអាយភីភីនិងសាម៉ីអង្គការជាសមាជិកនោះ។
ឃ. សមាជិកត្រូវគោរពតាមគោលនយោបាយ និងសេចក្តីណែនាំនានារបស់ អេអាយភីភីដែលបានព្រមព្រៀងក្នុងមហាសន្និបាត ដូចជាគោលនយោបាយហិរញ្ញវត្ថុ និងយ៉េនឌ័រ។
ង. សមាជិកត្រូវអនុវត្តតួនាទីរបស់ខ្លួន ក្នុងយន្តការនានាដែលបានបង្កើតឡើងដោយ អេអាយភីភី មានជាអាទ៍ គណកម្មាធិការកម្មវិធី។ សមាជិកក៏ត្រូវចូលរួមផងដែរក្នុងការសម្របសម្រួលអោយមាន យន្តការ ក្រុម និងដំណើការថ្នាក់តំបន់ និងអន្តរជាតិ។

**ផ្នែកទី៥** ការព្យួរ និងការដកសមាជិកភាព:

ក. សមាជិកភាពអាចនឹង ត្រូវគេព្យួរ នៅពេលណាដែលសមាជិកនោះ បានប្រព្រឹត្តិ ខុសទៅនិងធម្មនុញ្ញនិងលក្ខន្តិក:របស់ អេអាយភីភី។ ក្រុមប្រឹក្សាប្រតិបត្តិអាច ព្យួរ ជាបណ្តោះអាសន្ននូវសមាជិកភាពរបស់សមាជិកមួយដោយមានការពិគ្រោះយោបល់ ជាមួយសមាជិកផ្សេងទៀតនៅក្នុងអនុតំបន់។ ការសំរេចក្នុងការ ដកសមាជិកភាពរបស់សមាជិកណាមួយ នឹងសំរេចដោយមហាសន្និបាត។

ក្រុមប្រឹក្សាប្រតិបត្តិនឹងចាត់ទុកសមាជិកណាមួយថាអសកម្មនៅពេលដែលសមាជិកនោះ មិនមានទំនាក់ទំនងជាមួយលេខាធិការដ្ឋានតំបន់ និងមិនបានចូលរួមសកម្មភាពជាមួយ អេអាយភីភីចាប់ពីពីរឆ្នាំឡើងទៅ។ លេខាធិការដ្ឋាននឹងជូនដំណឹងដល់សមាជិកនោះតាមរយះសំបុត្រ។ មហាសន្និបាតនឹងពិនិត្យឡើងវិញនូវសមាជិកណាដែលអសកម្ម និងសំរេចចុងក្រោយថាត្រូវដក ឬព្យួរសមាជិកភាពរបស់សមាជិកណាមួយ។ សមាជិកដែលត្រូវគេព្យួរ ឬដកសមាជិកភាពអាចស្នើសុំចូលជាសមាជិកឡើងវិញតាមរយះក្រុមប្រឹក្សាប្រតិបត្តិ។
ខ. សមាជិកអាចសុំដកសមាជិកភាពរបស់ខ្លួនបានគ្រប់ពេលពី អេអាយភីភី។

## មាត្រា ២ មហាសន្និបាត: ការប្រជុំ និងភាគព្វកិច្ច

**ផ្នែកទី១** លេខាធិការដ្ឋាននឹងជូនដំណឹងដល់គ្រប់សមាជិក អេអាយភីភី អំពីការប្រជុំមហាសន្និបាតយ៉ាងតិច ៦០ថ្ងៃមុនកិច្ចប្រជុំ។

**ផ្នែកទី២** មហាសន្និបាតអាចប្រព្រឹត្តិទៅបានលុះត្រាតែមាន សមាជិកចូលរួមយ៉ាងតិច ពីរភាគបី (២/៣)។ ក្នុងករណីសមាជិកចូលរួមមិនគ្រប់ចំនួន ២/៣ ឬមិនមានអ្នកចូលរួម នោះមហាសន្និបាតចាំបាច់ត្រូវតែលើកទៅធ្វើនៅពេលក្រោយ។

**ផ្នែកទី៣** ភារៈកិច្ចរបស់សមាជិកដែលចូលរួមមហាសន្និបាតគឺដើម្បីៈ

ក. ពិនិត្យនូវស្ថានភាពរបស់ជនជាតិដើមភាគតិចនៅក្នុងតំបន់អាស៊ីទាំងមូល និងត្រូវធ្វើការពិភាក្សា និងអនុម័តលើ កម្មវិធី យុទ្ធសាស្រ្ត គោលនយោបាយ សេចក្តីសំរេចផ្សេងៗ និងផែនការសកម្មភាពរបស់ អេអាយភីភី។

ខ. ចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាប្រតិបត្តិ អគ្គលេខាធិការ និងប្រធាន។

គ. ស្តាប់របាយការណ៍ទូទៅ និងហិរញ្ញវត្ថុ ពីក្រុមប្រឹក្សាប្រតិបត្តិក្នុងអំឡុងពេលអនុវត្តកម្មវិធី អេអាយភីភី។

ឃ. អនុម័តលើសមាជិកភាពពេញលេញដែលនឹងចុះហត្ថលេខាទទួលស្គាល់ដោយក្រុមប្រឹក្សាប្រតិបត្តិ។

ង. ពិនិត្យ និងសំរេចទៅលើរចនាសម្ព័ន្ធស្ថាប័ន យន្តការ និងដំណើរការនានាក្នុងការធានាថាស្ថាប័នមួយនេះមានភាពរលូន។

ច. ផ្ទេរការងារទៅអោយក្រុមប្រឹក្សាប្រតិបត្តិ និងអគ្គលេខាអេអាយភីភី។

ឆ. ពិភាក្សា និងសំរេចទៅលើបញ្ហានានាដែលបាន លើកឡើងដោយសមាជិក អេអាយភីភិ។

ជ. អនុម័តទៅលើសមាជិកក្រុមប្រឹក្សាភិបាលរបស់ មូលនិធិ អេអាយភីភី។

ឈ. ធ្វើវិសោធនកម្ម និងអោយសច្ចាប័នទៅលើធម្មនុញ្ញ និងលក្ខន្តិកៈ អេអាយភីភី។

## មាត្រា ៣ ក្រុមប្រឹក្សាភិបាលៈ ការប្រជុំ និងភាតព្វកិច្ច

**ផ្នែកទី១** ក្រុមប្រឹក្សាភិបាលត្រូវតែជួបប្រជុំយ៉ាងតិចម្តងក្នុងមួយឆ្នាំ។

**ផ្នែកទី២** ខាងក្រោមនេះគឺជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សាភិបាលៈ

ក. ក្រុមប្រឹក្សាប្រតិបត្តិត្រូវគ្រប់គ្រង និងត្រួតពិនិត្យចំពោះហារិញ្ញវត្ថុ និងត្រូវពិនិត្យផងដែរនូវរបាយការណ៍សវនកម្មហិរញ្ញវត្ថុរបស់លេខាធិការដ្ឋាន។

ខ. ក្រុមប្រឹក្សាភិបាលត្រូវផ្តល់យោបល់ដល់ក្រុមប្រឹក្សាប្រតិបត្តិ និងអគ្គលេខាធិការចំពោះបញ្ហានានាពាក់ព័ន្ធនិងលក្ខ័ណ្ឌតម្រូវផ្សេងៗទាក់ទងនិងការចុះឈ្មោះស្របច្បាប់របស់អេអាយភីភី និងក្នុងពេលដែលក្រុមប្រឹក្សាប្រតិបត្តិស្នើសុំ។

## មាត្រា ៤ ក្រុមប្រឹក្សាប្រតិបត្តិ: ការប្រជុំ សមាសភាព និងភារកិច្ច

**ផ្នែកទី១** ក្រុមប្រឹក្សាប្រតិបត្តិត្រូវជួបប្រជុំគ្នារៀងរាល់ឆ្នាំ ឬយ៉ាងតិចជួបប្រជុំអោយបាន២ដងក្នុងចន្លោះមហាសន្និបាត។

**ផ្នែកទី២** កិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិគឺពីរភាគបី (២/៣) នៃសមាជិកក្រុមប្រឹក្សាប្រតិបត្តិ ទាំងអស់។ ក្នុងករណីសមាជិកចូលរួមមិនគ្រប់ចំនួន ២/៣ ឬមិនមានអ្នកចូលរួម នោះកិច្ចប្រជុំចាំបាច់ត្រូវតែលើកទៅធ្វើនៅពេលក្រោយ។

**ផ្នែកទី៣** អគ្គលេខាធិការ អាចកោះប្រជុំជាមួយក្រុមប្រឹក្សាប្រតិបត្តិក្នុងករណីបន្ទាន់ដោយត្រូវធ្វើការពិគ្រោះយោបល់ជាមួយប្រធាន អេអាយភីភី និងត្រូវជូនដំណឹងដល់ក្រុមប្រឹក្សាអំពីកិច្ចប្រជុំអោយបានយ៉ាងតិច៣០ថ្ងៃ។
ផ្នែកទី៤ ការចាត់តំណាងមក និងជ្រើសរើសសមាជិកក្រុមប្រឹក្សាប្រតិបត្តិត្រូវគិតអំពីលក្ខ័ណ្ឌ និងគុណវុឌ្ឍិដូចខាងក្រោម:

ក. ត្រូវតែជាមេដឹកនាំ ឬសមាជិកសកម្ម មកពីអង្គការសមាជិក អេអាយភីភី។
ខ. តែមានចំណេះដឹងមូលដ្ឋានអំពី អេអាយភីភី ទាំងស្ថាប័ន និងកម្មវិធី។
គ.ត្រូវតែមានការគាំទ្រ ឬអនុញ្ញាតិពីស្ថាប័នរបស់ខ្លួនដើម្បីក្លាយទៅជាក្រុមប្រឹក្សាប្រតិបត្តិ។
ឃ.ត្រូវមានប្រវត្តិល្អ ពាក់ព័ន្ធនឹងសេចក្តីថ្លៃថ្នូរ និងការអនុវត្តការងារនៅក្នុងស្ថាប័នរបស់ខ្លួន
ង.មានឆន្ទៈខ្ពស់ក្នុងការលើកកំពស់ និងធ្វើការសំរាប់សិទ្ធិ បញ្ហា និងសុខមាលភាពជនជាតិដើមភាគតិច។
ច. មានពេលវេលា និងឆន្ទៈដើម្បីបំពេញកាតព្វកិច្ច និងការទទួលខុសត្រូវក្នុងនាមជាសមាជិកនៃក្រុមប្រឹក្សាប្រតិបត្តិ រួមទាំងចូលរួមធ្វើការពេញម៉ោង ឬក្រៅម៉ោងជាមួយនិងអេអាយភីភី។

**ផ្នែកទី៥** ការជ្រើសរើសសមាជិកនៃក្រុមប្រឹក្សាប្រតិបត្តិត្រូវពិចារណារអោយបានល្អិតល្អន់អំពីសមតុល្យយ៉េនឌ័រ និងអាយុដើម្បីធានាថាយុវជន និងអ្នកចាស់ទុំបានចូលរួម។

**ផ្នែកទី៦** សមាជិកនៃក្រុមប្រឹក្សាប្រតិបត្តិត្រូវតែឆ្លងកាត់ការជ្រើសរើស ចេញពីតំណាងដែលមកពីអនុតំបន់និមួយៗដោយសមាជិកដែលមកពីអនុតំបន់នោះទៅតាមចំនួនដូចខាងក្រោម:

| លរ | អនុតំបន់ទាំង៤ | ចំនួនអង្គការសមាជិក | ចំនួនក្រុមប្រឹក្សាប្រតិបត្តិ |
|---|---|---|---|
| ១ | អាស៊ីខាងកើត: ជប៉ុន រុកគីយុស និង តៃវ៉ាន់/ចិន | ៦ | ១ |
| ២ | អាស៊ីអាគ្នេយ៍: ហ្វីលីពីន ទីម័រឡេសតេ ឥណ្ឌូនេស៊ី និងម៉ាឡេស៊ី | ៧ | ២ |
| ៣ | តំបន់មេគង្គ: វៀតណាម ឡាវ កម្ពុជា ថៃ និងភូមា | ១៣ | ២ |
| ៤ | អាស៊ីខាងត្បូង: នេប៉ាល់ ឥណ្ឌាជីគោក បង់ក្លាដេស និងឥណ្ឌាឥសាន | ១៧ | ៣ |
| | សរុប | | ៨ |
| ៥ | ប្រធាន និងអគ្គលេខាធិការ តាមរយៈការបោះឆ្នោត ដោយសមាជិកមហាសន្និបាត | | ២ |
| ៦ | តំណាងស្ត្រី និងយុវជន | | ២ |
| | សរុបរួម | ៤៣ | ១២ |

**ផ្នែកទី៧** តំណាងស្ត្រី និងយុវជនត្រូវតែចាត់មកដោយសមាជិកក្រុមយុវជន និងក្រុមស្ត្រីរៀងៗខ្លួន ហើយត្រូវតែទទួលស្គាល់ដោយមហាសន្និបាតទាំងមូល។

**ផ្នែកទី៨** អគ្គលេខាធិការ និងប្រធានត្រូវតែឆ្លងកាត់ការបោះឆ្នោតដោយមហាសន្និបាត។

**ផ្នែកទី៩** ការចាត់តាំង និងការជ្រើសរើសនូវប្រធាន អេអាយភីភី ត្រូវគោរពតាមលក្ខ័ណ្ឌ និងគុណវុឌ្ឍិដូចខាងក្រោម:

ក. ជាមេដឹកនាំ មកពីអង្គការសមាជិក អេអាយភីភី និងមានឆន្ទៈខ្ពស់ចំពោះជនជាតិដើមភាគតិច។

ខ. ធ្លាប់ចូលរួមយ៉ាងសកម្មជាមួយសកម្មភាពនានារបស់ អេអាយភីភី យ៉ាងតិច៣ឆ្នាំ។

គ. មានប្រវត្តិល្អ និងសេចក្តីថ្លៃថ្នូរ ក្នុងការធ្វើការងារជាមួយ និងដើម្បីជនជាតិដើមភាគតិច។

ឃ. មានជំនាញក្នុងការកំណត់បញ្ហា និងការព្រួយបារម្ភរបស់ជនជាតិដើមភាគ និងត្រូវមានបទពិសោធន៍ក្នុងការធ្វើការងារតស៊ូមតិនៅថ្នាក់ជាតិ តំបន់ និងឬថ្នាក់អន្តរជាតិយ៉ាងតិច៣ឆ្នាំ។

ង. មានចំណេះដឹងជ្រៅជ្រះអំពីបញ្ហាសិទ្ធិ និងការព្រួយបារម្ភរបស់ជនជាតិដើមភាគតិចយ៉ាងហោចណាស់ត្រឹមថ្នាក់ មូលដ្ឋាន ជាតិ និងតំបន់ ឬអន្តរជាតិ។

ច. មានពេលវេលា និងជំនាញដើម្បីបំពេញកាតព្វកិច្ច និងការទទួលខុសត្រូវក្នុងនាមជាប្រធាន ជាពិសេសចូលរួមធ្វើការពេញម៉ោង ឬក្រៅម៉ោងជាមួយនិង អេអាយភីភី (យ៉ាងតិច ១០ថ្ងៃក្នុងមួយខែ)។

**ផ្នែកទី១០** ការចាត់តាំង និងការជ្រើសរើស អគ្គលេខាធិការ អេអាយភីភី ត្រូវគោរពតាមលក្ខ័ណ្ឌ និងគុណវុឌ្ឍិដូចខាងក្រោម:

ក. ជាមេដឹកនាំ មកពីអង្គការសមាជិក អេអាយភីភី និងមានឆន្ទៈខ្ពស់ចំពោះជនជាតិដើមភាគតិច។

ខ. ធ្លាប់ចូលរួមយ៉ាងសកម្មជាមួយសកម្មភាពនានារបស់ អេអាយភីភី យ៉ាងតិច៣ឆ្នាំ។

គ. មានប្រវត្តិល្អ និងសេចក្តីថ្លៃថ្នូរ ក្នុងការធ្វើការងារជាមួយ និងដើម្បីជនជាតិដើមភាគតិច។

ឃ. មានជំនាញសរសេរ និងកំណត់នូវបញ្ហានិងការព្រួយបារម្ភរបស់ជនជាតិដើមភាគតិច និងត្រូវមានបទពិសោធន៍យ៉ាងតិច៣ឆ្នាំក្នុងការធ្វើការងារតស៊ូមតិ និងការងារជាបណ្តាញនៅកំរិតផ្សេងៗគ្នា រួមទាំងថ្នាក់អន្តរជាតិ។

ង. មានជំនាញក្នុងការសសេរសំណើ និងការស្វែងរកមូលនិធិ។

ច. មានចំណេះដឹងជ្រៅជ្រះអំពីជនជាតិដើមភាគតិចនៅថ្នាក់មូលដ្ឋាន និងមានបទពិសោធន៍ការងារពាក់ព័ន្ធនិងបញ្ហាជនជាតិដើមភាគតិចនៅថ្នាក់តំបន់ និងឬថ្នាក់អន្តរជាតិ។

ឆ. មានជំនាញគ្រប់គ្រង សម្របសម្រួល បណ្តាញ និងតស៊ូមតិ។

ជ. មានឆន្ទៈ និងការប្តេជ្ញាចិត្តខ្ពស់ដើម្បីធ្វើការពេញម៉ោងជាមួយលេខាធិការដ្ឋាន អេអាយភីភី។

**ផ្នែកទី១១** លេខាធិការដ្ឋានត្រូវចាត់តំណាងម្នាក់ក្នុងចំណោមបុគ្គលិក អេអាយភីភី ទាំងអស់ជាសមាជិកក្រុមប្រឹក្សាប្រតិបត្តិ ក្នុងឋានៈជាអ្នកតំណាងដែលមិនមានសិទ្ធិក្នុងការបោះឆ្នោតឡើយ។

**ផ្នែកទី១២** ក្នុងករណីដែលសមាជិកលាឈប់ជាក្រុមប្រឹក្សាប្រតិបត្តិ នោះក្រុមប្រឹក្សាប្រតិបត្តិនឹងស្នើទៅសមាជិកនៅក្នុងអនុតំបន់ដែលបានលាឈប់នោះដើម្បីអោយពួកគេចាត់តំណាងអោយធ្វើជាក្រុមប្រឹក្សាប្រតិបត្តិជំនួស ហើយផ្ញើទៅក្រុមប្រឹក្សាប្រតិបត្តិតាមរយៈប្រធានអោយបានលឿនតាម

ដែលអាចធ្វើបាន។ ក្នុងករណីដែលសមាជិកនៅក្នុងអនុតំបន់នោះមិនមានការយល់ស្របគ្នាចំពោះការចាត់តាំងអ្នកជំនួសថ្មី ក្រុមប្រឹក្សាប្រតិបត្តិនឹងចាត់តាំង អ្នកតំណាងម្នាក់ពីក្រុមប្រឹក្សាប្រតិបត្តិសំរាប់ ពិគ្រោះយោបល់ សម្របសម្រួល និងទំនាក់ទំនងជាមួយនិងថ្នាក់តំបន់រហូតដល់មានការព្រមព្រៀង។

**ផ្នែកទី១៣** ក្រុមប្រឹក្សាប្រតិបត្តិមានសិទ្ធិផ្តាច់មុខក្នុងការកំណត់ប្រភេទនៃសមាជិករបស់ខ្លួនក្នុងករណីដែលសមាជិកណាម្នាក់មិនមានទំនាក់ទំនង ឬមិនបានចូលរួមប្រជុំក្រុមប្រឹក្សាប្រតិបត្តិ២ដងជាប់គ្នាដោយមិនមានមូលហេតុច្បាស់លាស់ និងសមស្រប។ នៅក្នុងស្ថានភាពបែបនេះក្រុមប្រឹក្សាប្រតិបត្តិនឹងទំនាក់ទំនងទៅសមាជិកពាក់ព័ន្ធនៅក្នុងអនុតំបន់នោះដើម្បីជូនដំណឹងអំពីសមាជិកដែលមិនសកម្មនោះ ព្រមទាំងស្នើសុំយោបល់ និងអនុសាសន៍របស់សមាជិកពាក់ព័ន្ធទាំងនោះ។ ក្នុងករណីតម្រូវអោយមានការផ្លាស់ប្តូរនោះ សមាជិកពាក់ព័ន្ធនៅក្នុងអនុតំបន់នោះត្រូវចាត់អ្នកតំណាងថ្មីក្នុងរយៈពេលយ៉ាងយូរ៦ខែឬអោយបានមុនពេលកិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិប្រសិនបើមានពេលវេលាគ្រប់គ្រាន់ ឬការជ្រើសរើសតំណាងថ្មីជំនួសអាចធ្វើបានក្នុងពេលប្រជុំតាមអនុតំបន់នោះ។ ក្នុងករណីសមាជិកក្នុងអនុតំបន់មិនអាចចាត់តំណាងថ្មីជំនួស ឬមិនអាចឈានដល់ការព្រមព្រៀង នោះក្រុមប្រឹក្សាប្រតិបត្តិនឹងចាត់តាំងសមាជិកម្នាក់ពីក្នុងក្រុមដើម្បីទទួលខុសត្រូវលើអនុតំបន់នោះក្នុងអណត្តិដែលនៅសេសសល់។

**ផ្នែកទី១៤** ក្នុងករណីដែលសមាជិកណាមួយនៃក្រុមប្រឹក្សាប្រតិបត្តិប្រព្រឹត្តិល្មើសនិងគោលនយោបាយ និងគោលការណ៍របស់ អេអាយភីភី ឬសង្ស័យថាមានទាក់ទងនិងទំនាស់ផលប្រយោជន៍ នោះអង្គការសមាជិកអាចអោយអនុសាសន៍ទៅក្រុមប្រឹក្សាប្រតិបត្តិដើម្បីចាត់វិធានការទប់ស្កាត់តាមរយៈប្រធាន។ វិធានការនានាដែលធ្វើឡើងដោយប្រធាននឹងត្រូវសង្កេតតាមដានដោយក្រុមប្រឹក្សាប្រតិបត្តិដែលវិធានការទាំងនោះអាចជាព្យួរសមាជិកភាពបណ្តោះអាសន្ន រហូតដល់ដកសមាជិកភាពជាក្រុមប្រឹក្សាប្រតិបត្តិ។ សំរាប់ការជ្រើសរើសអ្នកតំណាងជំនួសត្រូវអនុវត្តតាមជំហាននានាដែលបានចែងក្នុងផ្នែកទី៥នៃមាត្រានេះ។

ផ្នែកទី១៥ ក្រុមប្រឹក្សាប្រតិបត្តិនឹងធ្វើគ្រប់ជំហានក្នុងការកោះហៅបើកមហាសន្និបាតដើម្បីជ្រើសតាំងអគ្គលេខាធិការថ្មីក្នុងករណីដែលអគ្គលេខាធិការចាស់លាឈប់មុនពេលបញ្ចប់អាណត្តិ។ ក្រុមប្រឹក្សាប្រតិបត្តិអាចជ្រើសតាំងអគ្គលេខាធិការស្តីទី ចេញពីសមាជិករបស់ខ្លួនក្នុងរយៈពេលបណ្តោះអាសន្ន។

**ផ្នែកទី១៦** ខាងក្រោមនេះគឺជាមុខងារ និងតួនាទីទូទៅរបស់ក្រុមប្រឹក្សាប្រតិបត្តិ

ក. ក្រុមប្រឹក្សាប្រតិបត្តិជាអ្នកមានតួរនាទីក្នុងការសំរេចចិត្តសំរាប់ស្ថាប័នទាំងមូលក្នុងចន្លោះពេលមហាសន្និបាត។

ខ. មុខងារចំបងរបស់ក្រុមប្រឹក្សាប្រតិបត្តិគឺគ្រប់គ្រង និងដឹកនាំ អេអាយភីភី។ មុខងារទាំងនោះរួមទាំងអនុវត្តផែនការយុទ្ធសាស្ត្រ តាមតួរនាទីការងារ សេចក្តីណែនាំ និងអាណត្តិដែលបានដាក់ចេញដោយមហាសន្និបាត។

គ. ក្រុមប្រឹក្សាប្រតិបត្តិត្រូវបង្កើតគោលនយោបាយ និងសេចក្តីណែនាំដែលល្អដើម្បីអោយអេអាយភីភី អាចធ្វើប្រតិបត្តិការរបស់ខ្លួនដោយរលូន និងសំរេចជោគជ័យទៅតាមគោលការណ៍ គោលដៅ និងគោលបំណងរបស់ស្ថាប័ន។

ឃ. ក្រុមប្រឹក្សាប្រតិបត្តិត្រូវទទួល និងធ្វើសកម្មភាពទៅតាមការណែនាំ ការផ្តល់យោបល់អនុសាសន៍ និងបញ្ហាផ្សេងៗទៀតដែលទាក់ទងនឹងការងារ អេអាយភីភី ពីសមាជិករបស់ខ្លួន រួមទាំងធ្វើការវាយតំលៃនូវមុខងាររបស់ អេអាយភីភី។

ង. ក្រុមប្រឹក្សាប្រតិបត្តិត្រូវផ្ទេរសិទ្ធិទៅអគ្គលេខាធិការដើម្បីដោះស្រាយនូវរាល់អនុសាសន៍ទាក់ទងនឹងយុទ្ធសាស្ត្រ និងការអនុវត្តន៍របស់កម្មវិធីដោយរួមទាំងការស្វែងរកមូលនិធិដើម្បីគាំទ្រសកម្មភាព និងកម្មវិធីរបស់ អេអាយភីភី។

ច. ក្រុមប្រឹក្សាប្រតិបត្តិនឹងទទួល និងពិនិត្យរាល់របាយការណ៍នៃសកម្មភាពការងារដែលអនុវត្តដោយអគ្គលេខាធិការដែលទាក់ទងទៅនិងការងារ និងតួនាទីរបស់អគ្គលេខាធិការ។

ឆ. ក្រុមប្រឹក្សាប្រតិបត្តិ ទទួលខុសត្រូវ រៀបចំមហាសន្និបាត ដោយរួមទាំងការរៀបចំរបាយការណ៍ក្រុមប្រឹក្សាប្រតិបត្តិដោយមានការជួយគាំទ្រពីសមាជិកលេខាធិការដ្ឋាន។

ជ.ក្រុមប្រឹក្សាប្រតិបត្តិទទួលរបាយការណ៍សាវនកម្មហិរញ្ញវត្ថុ និងអនុម័តលើថវិការប្រចាំឆ្នាំដើម្បីគាំទ្រដល់រាល់សកម្មភាព និងកម្មវិធីរបស់ អេអាយភីភី។

ឈ. ក្រុមប្រឹក្សាប្រតិបត្តិជាអ្នករៀបចំប្រជុំគណៈកម្មាធិការកម្មវិធីរបស់ អេអាយភីភិ។

ញ.ក្រុមប្រឹក្សាប្រតិបត្តិធ្វើរាល់សកម្មភាពចាំបាច់ដើម្បីលើកកំពស់ និងអនុវត្តន៍នូវគោលដៅនិងគោលបំណងរបស់ អេអាយភីភី និងរាយការណ៍ជូនដល់អង្គមហាសន្និបាត។

**ផ្នែកទី១៧** សមាជិកក្រុមប្រឹក្សាប្រតិបត្តិម្នាក់ៗមានតួរនាទី និងកាតព្វកិច្ចដូចតទៅ:

ក.ភ្ជាប់ រក្សាទំនាក់ទំនងទៀងទាត់ និងឆ្លើយតបនូវរាល់ការងារដែលទាក់ទងនិងក្រុមប្រឹក្សាប្រតិបត្តិ។

ខ. ចូលរួមរាល់កិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិ តាមប្រព័ន្ធទូរគមនាគមន៍។

គ. ចូលរួមរាល់កិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិ។

ឃ. រៀបចំ និងសម្របសម្រួលរាល់កិច្ចប្រជុំតាមអនុតំបន់របស់ខ្លួនដោយពិភាក្សាយោបល់ជាមួយអគ្គលេខាធិការ និងដោយមានជំនួយការពីអគ្គលេខាធិការរង និងសមាជិករបស់លេខាធិការដ្ឋាន។
ង. ចូលរួមរាល់សកម្មភាពរបស់ អេអាយភីភីដែលទាក់ទងការងារខ្លួន និងរាល់ពេលដែលមានការស្នើសុំ។
ច. ជាតំណាងអោយ អេអាយភីភី ដោយភាពសមរម្យ។
ឆ. ចងជាបណ្តាញ និងជួយក្នុងការពង្រឹងស្ថាប័ន នៅតាមអនុតំបន់របស់ខ្លួន។
ជ.ជួយក្នុងដំណើរការធ្វើការពិនិត្យ និងផ្ទៀងផ្ទាត់នូវអង្គការដែលដាក់ពាក្យចូលជាសមាជិកដែលមកពីអនុតំបន់របស់ខ្លួន ដោយពិភាក្សាយោបល់ជាមួយសមាជិកដទៃទៀតដែលនៅក្នុងអនុតំបន់ជាមួយគ្នា។
ឈ. ជាអ្នករៀបចំ និងសហការរៀបចំរាល់កិច្ចប្រជុំយ៉ាងតិចមួយកម្មវិធីរបស់ អេអាយភីភី និងរក្សានូវការសម្របសម្រួលជិតស្និទ្ធជាមួយសមាជិកលេខាធិការដ្ឋាន។
ញ. ផ្តល់ដំបូន្មាន និងមគ្គុទេសន៍ដល់ការរៀបចំផែនការ និងការអនុវត្តន៍គម្រោង។
ដ.ជួយក្នុងការសំភាសន៍បុគ្គលិកដែលដាក់ពាក្យមកពីអនុតំបន់ដែលខ្លួនទទួលខុសត្រូវតាមចាំបាច់។
ឋ. បំពេញការងារផ្សេងៗទៀតដែលដាក់អោយដោយក្រុមប្រឹក្សាប្រតិបត្តិ។

## មាត្រា ៥ គណៈកម្មាធិការកម្មវិធី: សមាសភាព និងតួនាទី

**ផ្នែកទី១** សមាសភាព និងលក្ខណ្ឌរបស់គណៈកម្មាធិការកម្មវិធីៈ

- ជាអ្នកតំណាងដែលចាត់តាំងដោយអង្គការសមាជិកដែលមានជំនាញ ចំណេះដឹង និងមានពេលវេលាដើម្បីធ្វើជាសមាជិកគណៈកម្មាធិការកម្មវិធីសកម្ម។
- ជាមេដឹកនាំជនជាតិដើមភាគតិចមកពីបណ្តាញណាមួយដែលមានបទពិសោធន៍ទៅលើកម្មវិធីណាមួយរបស់ អេអាយភីភី និង/ឬ មានបទពិសោធន៍ផ្ទាល់ជាមួយបញ្ហានានាដែលពាក់ព័ន្ធជាមួយកម្មវិធីជាក់លាក់ណាមួយនៅក្នុងស្ថាប័នឬសហគមន៍របស់ពួកគេ។
- លក្ខ័ណ្ឌទូទៅដែលត្រូវពិចារណាក្នុងពេលបង្កើតសមាសភាពគណកម្មាធិការកម្មវិធីរួមមាន សមតុល្យយ៉ែនឌ័រ អាចតំណាងអោយអនុតំបន់ យ៉ែនឌ័រនិងការចូលរួមរបស់យុវជន។

**ផ្នែកទី២** អង្គការសមាជិកអាចជំនួសអ្នកតំណាងរបស់ខ្លួនសំរាប់គណកម្មាធិការកម្មវិធីតាមរយៈការជូនដំណឹងដោយមានមូលហេតុសមរម្យទៅក្រុមប្រឹក្សាប្រតិបត្តិដែលទទួលខុសត្រូវតាមតំបន់ អគ្គលេខាធិការ និងអ្នកសម្របសម្រួលកម្មវិធីនោះ។

**ផ្នែកទី៣** សមាជិកគណកម្មាធិការកម្មវិធីណាមួយដែលដាច់ទំនាក់ទំនងចាប់ពីមួយឆ្នាំជាមួយ អេអាយភីភី ឬ មិនបានចូលរួមនៅក្នុងកិច្ចប្រជុំគណកម្មាធិការកម្មវិធី ឬសកម្មភាពនឹងចាត់ទុកថាជាសមាជិកអសកម្ម។ គណកម្មាធិការកម្មវិធីនឹងជូនដំណឹងជាមុន បន្ទាប់មករើសអ្នកតំណាងជំនួសដោយពិភាក្សាជាមួយសមាជិកដទៃៗទៀតនៅក្នុងអនុតំបន់ជាមួយគ្នា។

**ផ្នែកទី៤** អ្នកជំនាញជនជាតិដើមភាគតិចដែលដាច់ទំនាក់ទំនងចាប់ពីមួយឆ្នាំជាមួយ អេអាយភីភី ឬ មិនបានចូលរួមនៅក្នុងកិច្ចប្រជុំគណកម្មាធិការកម្មវិធីនឹងចាត់ទុកថាជា សមាជិកអសកម្ម។ គណកម្មាធិការកម្មវិធីនឹងជូនដំណឹងជាមុន បន្ទាប់មករើសអ្នកតំណាងជំនួសដោយពិភាក្សាជាមួយក្រុមប្រឹក្សាប្រតិបត្តិនៅក្នុងអនុតំបន់នោះ និងអគ្គលេខាធិការ។

**ផ្នែកទី៥** មុខងារចំបងរបស់គណកម្មាធិការកម្មវិធី អេអាយភីភីគឺផ្តល់ដំបូន្មាន និងមគ្គុទេសន៍ទៅបុគ្គលិកអនុវត្តកម្មវិធី និងរាល់សកម្មភាពដែលនៅក្រោមកម្មវិធីនោះ។

**ផ្នែកទី៦** គណកម្មាធិការ ត្រូវរៀបចំកិច្ចប្រជុំយ៉ាងតិចអោយបានម្តងក្នុងកំឡុងពីរឆ្នាំដើម្បីវាយតំលៃទៅលើវឌ្ឍនភាព នៃការអនុវត្តន៍ការងារខ្លួននៅឆ្នាំចាស់ និងរៀបចំផែនការសំរាប់សកម្មភាពដែលនឹងធ្វើនៅពេលអនាគត។

**ផ្នែកទី៧** គណកម្មាធិការត្រូវទទួលយក និងដោះស្រាយនូវរាល់មតិយោបល់ អនុសាសន៍ និងបញ្ហាផ្សេងៗទៀតដែលលើកឡើងដោយសមាជិក អេអាយភីភី ពាក់ព័ន្ធនិងការអនុវត្តន៍សកម្មភាព និងកម្មវិធីដោយពិភាក្សាជាមួយ អគ្គលេខាធិការ ឬអគ្គលេខាធិការរង និងប្រធាន។

**ផ្នែកទី៨** ដោយមានការជួយគាំទ្រពីអគ្គលេខាធិការ ឬអគ្គលេខាធិការរង និងពីអ្នកសម្របសម្រួលកម្មវិធី នោះអ្នកតំណាងក្រុមប្រឹក្សាប្រតិបត្តិដែលក៏ជាសមាជិកគណកម្មាធិការកម្មវិធីត្រូវសកម្មក្នុងផ្តល់ជាមគ្គុទេសន៍សំរាប់ការធ្វើផែនការ និងការអនុវត្តន៍កម្មវិធី។

**ផ្នែកទី៩** ក្រុមប្រឹក្សាប្រតិបត្តិដែលជាសមាសភាពនៅក្នុងគណកម្មាធិការកម្មវិធី អាចផ្ទេរការងាររបស់ខ្លួនទៅអោយសមាជិកក្រុមប្រឹក្សាប្រតិបត្តិដទៃទៀតទៅតាមករណីមួយទៅករណីមួយទៀតតាមស្ថានភាពជាក់ស្តែង។

**ផ្នែកទី១០** គណកម្មាធិការកម្មវិធី ត្រូវធ្វើរាល់សកម្មភាព និងការងារដែលចាំបាច់ដើម្បីលើកកំពស់ និងសំរេចបាននូវគោលដៅ និងគោលបំណងរបស់ អេអាយភីភី។ គណកម្មាធិការកម្មវិធីត្រូវធ្វើរបាយការណ៍អំពីវឌ្ឍនភាពការងាររបស់ខ្លួនទៅក្រុមប្រឹក្សាប្រតិបត្តិតាមរយៈអ្នកតំណាងពីក្រុមប្រឹក្សាប្រតិបត្តិនៅក្នុងគណកម្មាធិការកម្មវិធី។

**ផ្នែកទី១១** នៅក្នុងលក្ខ័ណ្ឌណាមួយដែលគណកម្មាធិការកម្មវិធីមិនមានដំណើរដោយប្រក្រតីដោយសារមានសមាជិកអសកម្មនោះ តាមរយៈអគ្គលេខាធិការឬអគ្គលេខាធិការរង លេខាធិការដ្ឋានដោយធ្វើការពិគ្រោះយោបល់ជាមួយសមាជិកក្រុមប្រឹក្សាប្រតិបត្តិដែលទទួលខុសត្រូវត្រូវអោយអនុសាសន៍ដើម្បីធ្វើយ៉ាងណាអោយគណកម្មាធិការកម្មវិធីមានដំណើរឡើងវិញ។

## មាត្រា ៦ និតិវិធី

**ផ្នែកទី១** អេអាយភីភី ត្រូវលើកកំពស់និងទទួលយកនូវដំណើរការសំរេចចិត្តជាកុងសង់ស៊ីស (ព្រមព្រៀងគ្នាជាក្រុម)។ ប្រសិនបើមិនអាចឈានទៅដល់ការព្រមព្រៀងគ្នាជាក្រុមទេ នោះការសំរេចចិត្តត្រូវធ្វើឡើងតាមការបោះឆ្នោត មួយសំលេង ក្នុងមួយប្រទេសឬក្នុងមួយតំបន់ដែលអេអាយភីភីបានបែងចែក។ ការសំរេចចិត្តត្រូវធ្វើឡើងតាមដំណើរការដូចខាងក្រោម:

- ការបោះឆ្នោតត្រូវធ្វើក្នុងចំណោមសមាជិកនៅក្នុងប្រទេស ឬអនុតំបន់ដើម្បីសំរេចទៅលើសំលេងឆ្នោត។ បន្ទាប់មក ប្រទេសឬអនុតំបន់នឹងធ្វើការបោះឆ្នោតនៅក្នុងអង្គមហាសន្និបាត។

## មាត្រា ៧ លេខាធិការដ្ឋានរបស់ អេអាយភីភី

**ផ្នែកទី១** សមាសភាពរបស់លេខាធិការដ្ឋានត្រូវអាស្រ័យលើតំរូវការនៃការអនុវត្តន៍កម្មវិធី និងសមត្ថភាពហិរញ្ញវត្ថុរបស់ អេអាយភីភី។

**ផ្នែកទី២** អគ្គលេខាធិការ និងក្រុមប្រឹក្សាប្រតិបត្តិត្រូវកំណត់នូវតួរនាទី និងការទទួលខុសត្រូវ ក៏ដូចជា លក្ខ័ណ្ឌយោងសំរាប់អគ្គលេខាធិការរង។ ហើយអគ្គលេខាធិការ និងក្រុមប្រឹក្សាប្រតិបត្តិត្រូវវាយតំលៃការបំពេញការងាររបស់អគ្គលេខាធិការរងអោយបានទៀងទាត់។

**ផ្នែកទី៣** រាល់ការប្រតិបត្តិការងាររបស់លេខាធិការដ្ឋាន ត្រូវយោងទៅតាមសេចក្តីណែនាំ និងគោលនយោបាយបុគ្គលិក អេអាយភីភី ដែលបានអនុម័តដោយក្រុមប្រឹក្សាប្រតិបត្តិ និងអាចធ្វើការពិនិត្យឡើងវិញយោងទៅតាមសំណើរ ឬអនុសាសន៍ពីបុគ្គលិកលេខាធិការដ្ឋាន ឬសមាជិកណាមួយនៃក្រុមប្រឹក្សាប្រតិបត្តិ។

**ផ្នែកទី៤** លេខាធិការដ្ឋានអាចជួល ឬជ្រើសរើសអ្នកស្ម័គ្រចិត្តដោយយោងទៅតាមតំរូវការ និងភាពចាំបាច់សំរាប់ការគ្រប់គ្រង និងលក្ខ័ណ្ឌដទៃៗទៀត។

**ផ្នែកទី៥** តួនាទី និងកាតព្វកិច្ចរបស់បុគ្គលិកលេខាធិការដ្ឋានរបស់ អេអាយភីភីមានដូចតទៅ:

ក. បុគ្គលិកលេខាធិការដ្ឋានត្រូវវាយការណ៍អំពីវឌ្ឍនភាពការងាររបស់ខ្លួនទៅក្រុមប្រឹក្សាប្រតិបត្តិតាមរយ:អគ្គលេខាធិការ។

ខ. បុគ្គលិកលេខាធិការដ្ឋានត្រូវទទួលខុសត្រូវក្នុងការរៀបចំគម្រោងសំណើរ របាយការណ៍ និងរបាយការណ៍ហិរញ្ញវត្ថុដាក់ជូនទៅម្ចាស់ជំនួយ រួមទាំងរបាយការណ៍ប្រចាំឆ្នាំរបស់ អេអាយភីភី ផងដែរ។

គ. បុគ្គលិកលេខាធិការដ្ឋានត្រូវគោរពតាម និងអនុវត្តតាមរាល់សេចក្តីណែនាំ និងគោលនយោបាយរបស់ អេអាយភីភី។

## មាត្រា ៨ ប្រសិទ្ធភាព និង វិសោធនកម្ម

**ផ្នែកទី១** ធម្មនុញ្ញ និងលក្ខន្តិក:នេះនឹងចូលជាធរមានភ្លាមបន្ទាប់ពីសមាជិកផ្តល់សច្ចាប័ន។